**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភូមិអន្លង់ស្វាយ
# សម្រាប់រយៈពេល ៣ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភូមិអន្លង់ស្វាយ |
| ភូមិ | ៖ | អន្លង់ស្វាយ |
| ឃុំ | ៖ | ព្រះរំកិល |
| ស្រុក | ៖ | ថាឡាបរីវ៉ាត |
| ខេត្ត | ៖ | ស្ទឹងត្រែង |

**ខែកុម្ភៈ ឆ្នាំ២០១៩**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

# ភូមិអន្លង់ស្វាយ

## សម្រាប់រយៈពេល ៣ឆ្នាំ

## (កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភូមិអន្លង់ស្វាយ |
| ភូមិ | ៖ | អន្លង់ស្វាយ |
| ឃុំ | ៖ | ព្រះរំកិល |
| ស្រុក | ៖ | ថាឡាបរិវ៉ាត់ |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ខែកុម្ភៈ ឆ្នាំ២០១៩

# មាតិកា


**១. ស្ថានភាពទូទៅ** ............ ៣

**២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ............ ៤

ក. ប្រជាពលរដ្ឋ ............ 4

ខ. មុខរបរ ............ ៤

**៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ** ............ ៥

ក. ទីតាំង ............ ៥

ខ. ដែននេសាទ ............ ៥

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ............ ៥

ឃ.ធនធានជលផល ............ ៦

**៤. ការធ្វើនេសាទ** ............ ៦

ក. អ្នកនេសាទ ............ ៦

ខ. ឧបករណ៍នេសាទ ............ ៦

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ............ ៧

**៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ............ ៧

ក.ទស្សនៈវិស័យ ............ ៧

ខ. គោលបំណងរួម ............ ៧

គ. គោលបំណងជាក់លាក់ ............ ៨

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............ ៨

ឃ.១. ធនធានជលផល និងអេកូឡូស៊ី ............ ៨

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ............ ៩

ឃ.៣. ការគ្រប់គ្រង ............ ១២

ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ............ ១៤

ច. យុទ្ធសាស្ត្រ ............ ១៤

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២)** ............ ១៦

**តារាងកម្មវិធីការងារប្រចាំឆ្នាំ កក្កដា ២០១៩ - មិថុនា ២០២២** ............ ២២

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទភូមិអន្លង់ស្វាយ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៧ ហើយបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១ សម្រាប់រយៈពេលបីឆ្នាំ គឺចាប់ពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១២ និងត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០។ សហគមន៍នេសាទនេះមានទីតាំងស្ថិតនៅក្នុងភូមិអន្លង់ស្វាយ ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន២១៨នាក់ ស្រីចំនួន១១២នាក់ ស្មើនឹង៨៧គ្រួសារ និងមានគណៈកម្មការចំនួន០៧នាក់ ស្រីចំនួន០១នាក់។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមក សហគមន៍នេសាទបានអនុវត្តសកម្មភាពសំខាន់ៗដូចជា ការរៀបចំរចនាសម្ព័ន្ធរបស់គណៈកម្មការ រៀបចំបញ្ជីឈ្មោះសមាជិក និងគណៈកម្មការ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ការចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ ការរៀបចំ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទ ការរៀបចំក្រុមល្បាត ការចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ការចុះល្បាតជាប្រចាំដោយសហការជាមួយសមត្ថកិច្ចជលផល អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលដែលកើតមាននៅក្នុងកន្លែងនេសាទសហគមន៍ភូមិអន្លង់ស្វាយ។

ចាប់ពីឆ្នាំ២០០៩ រហូតដល់បច្ចុប្បន្ន សហគមន៍នេសាទបានធ្វើការអះអាងពីភាពរីកចម្រើនរបស់សហគមន៍នេសាទក្នុងការកាត់បន្ថយការកាប់បំផ្លាញព្រៃលិចទឹក និងកាត់បន្ថយសកម្មភាពបទល្មើសនេសាទនានា ដោយមានការទំនាក់ទំនង និងសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញជលផល មន្ទីរបរិស្ថាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ដែលធ្វើឱ្យផលនេសាទមានការកើនឡើង។ ម្យ៉ាងទៀតការរីកចម្រើននេះ ដោយសារតែអ្នកភូមិមានការយល់ដឹង ក្នុងការចូលរួមពីសហគមន៍ និងការកើនឡើងនូវតម្រូវការធនធានធម្មជាតិ ជាពិសេសធនធានជលផល។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទជួបប្រទះនូវបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រង ៖

បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ីរួមមានផលប៉ះពាល់អវិជ្ជមាន ពីទំនប់វារីអគ្គិសនីដនសាហុង ការកាប់បំផ្លាញព្រៃលិចទឹក ត្រីខ្វះជម្រកពងកូន ការបង្ហូរសំណល់រាវ និងសំណល់រឹងចូលក្នុងទឹកទន្លេ និងការបាត់បង់ត្រីពូជមួយចំនួនដូចជាត្រីគល់រាំង ត្រីប្រា ត្រីក្រសក់ ត្រីប្រម៉ា ត្រីព្រួល ។ល ។

បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានខ្វះដើមទុនប្រកបមុខរបរ គ្មានជំនាញច្បាស់លាស់ក្នុងការប្រកបរបរចិញ្ចឹមជីវិត ខ្វះទីផ្សារលក់ផលិតផល ខ្វះទឹកស្រោចស្រពធ្វើដំណាំកសិកម្ម ខ្វះជំនាញចិញ្ចឹមត្រី ប្រាក់ចំណូលទាប

ចំណេះដឹងនៅមានកម្រិត ខ្វះមុខរបរនិងការងារ ធ្វើចំណាកស្រុកទៅរកការងារ ទីតាំងភូមិឆ្ងាយពីទីប្រជុំជន និងមន្ទីរសុខភាព និងផ្លូវពិបាកធ្វើដំណើរ ។

បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ឧបករណ៍ទំនើប ខ្វះសម្ភារ និងមធ្យោបាយបង្ក្រាបបទល្មើសនេសាទ សមត្ថភាពគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ ព្រមទាំងការសហការជាមួយអ្នកពាក់ព័ន្ធនៅមានកម្រិត ខ្វះការចូលរួមពីប្រជាពលរដ្ឋក្នុងការអភិរក្ស និងទប់ស្កាត់បទល្មើសនេសាទ ប្រជាពលរដ្ឋការយល់ដឹងច្បាប់ស្តីពីជលផលនៅមានកម្រិត សមាជិកសហគមន៍យល់ថាការងាររបស់គណៈកម្មការជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ទោះបីស្ត្រីចូលរួមក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន ប៉ុន្តែការសម្រេចនៅមានកម្រិត ។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងតំបន់នៃសហគមន៍ សរុបមានចំនួន៨៧៥នាក់ ស្ត្រី៣៥១នាក់ ស្មើនឹង២០៦គ្រួសារ ជនជាតិខ្មែរ១០០% ។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន១០០%។

សមាជិកសហគមន៍នេសាទភូមិអន្លង់ស្វាយ មានស្ថានភាពដូចខាងក្រោម ៖

- ចំនួនស្ត្រីជាមេគ្រួសារមាន១៩ នាក់
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១៩ នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន០៥ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន០៣ នាក់ ស្រី០២នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទ០២នាក់ ស្រី០១នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន១១នាក់ ស្រី០៣នាក់
- កម្រិតសិក្សាអប់រំរួមមាន អ្នកមិនចេះអក្សរមានចំនួន១៨២នាក់ ស្រី១០៣នាក់ ថ្នាក់បឋមសិក្សាចំនួនសរុប ១៤០ នាក់ ស្រី៦៤នាក់ អនុវិទ្យាល័យចំនួនសរុប១៥នាក់ ស្រី១១នាក់ វិទ្យាល័យចំនួនសរុប០៣នាក់ ស្រី ០០នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងតំបន់សហគមន៍នេះរួមមាន ៖

- ធ្វើនេសាទជាលក្ខណៈគ្រួសារចំនួន១៦៥ គ្រួសារត្រូវនឹង៨០%
- ធ្វើស្រែចំនួន១៥៥ គ្រួសារ ដែលមានទំហំដីចំនួន១៥៨ ហិកតា
- ដាំបន្លែជាលក្ខណៈគ្រួសារចំនួន៥០ គ្រួសារ (សួនច្បារជាលក្ខណៈគ្រួសារដែលមានទំហំ៥x១០ ម៉ែត្រ)
- ជាងផ្ទះមានចំនួន០៥គ្រួសារ
- ធ្វើចំការចំនួន៤១គ្រួសារ ទំហំដីចំការ៨១ហិកតា ដែលមានដំណាំចម្រុះដូចជា ពោត សណ្តែក ល្ង ស្រូវ ដំឡូង និងចន្ទី

- ធ្វើសិប្បកម្មគ្រឿងសង្ហារឹមចំនួន០១គ្រួសារ
- លក់ដូរជាអាជីព ចំនួន១២គ្រួសារ
- ចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ចំនួន៥០ % នៃចំនួនគ្រួសារក្នុងភូមិ
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួន១០គ្រួសាររួមមានផ្អក ប្រហុក ត្រីប្រៃ ជាដើម។ ក្នុងមួយគ្រួសារ អាចផលិតបានពី០៥ គីឡូក្រាម ទៅ១៥ គីឡូក្រាមក្នុង១ឆ្នាំ
- ស៊ីឈ្នួលចំនួន៣០គ្រួសារ
- មន្ត្រីរាជការចំនួន២៥នាក់ ស្រី១២នាក់
- ចំណាកស្រុកចំនួន៨៥ នាក់ ស្រី៤១ នាក់
- គ្រូបង្រៀនចំនួន៣១នាក់

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក. ទីតាំង

កន្លែងនេសាទសហគមន៍ភូមិអន្លង់ស្វាយ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍ភូមិអន្លង់ស្វាយមានទំហំ១៥៨ ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងព្រំប្រទល់ប្រទេសកម្ពុជាជាមួយប្រទេសឡាវ
- ខាងត្បូងទល់នឹងភូមិលើ ឃុំកោះស្នែង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
- ខាងកើតទល់នឹងកោះលូ ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
- ខាងលិចទល់នឹងព្រំប្រទល់ខេត្តព្រះវិហារ ជាមួយខេត្តចំប៉ាសាក់ ប្រទេសឡាវ

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ភូមិអន្លង់ស្វាយមានវិសាលភាពនៅក្នុងទន្លេមេគង្គ និងមានអន្លង់ចំនួន០១៖

- ក្នុងទន្លេមេគង្គមានទំហំ១.៥០០ ហិកតា ដែលប្រជាពលរដ្ឋធ្វើនេសាទពេញ១ឆ្នាំ
- អន្លង់អូរឈើទាលមានទំហំ០៧ ហិកតា។

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សហគមន៍នេសាទភូមិអន្លង់ស្វាយបានឯកភាពគ្នាយកតំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន០១ កន្លែង គឺ អន្លង់អូរឈើទាល ទំហំ០៧ ហិកតា។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់អូរឈើទាល | ៥០០ x ៧០០ | ៣៥០.០០០ | ៥៨ | ១០ |

ឃ.ធនធានជលផល

១.ប្រភេទត្រី

ត្រីរ៉ស់ ត្រីប៉ាស៊ីអ៊ី ត្រីព្រួល ត្រីប្រា ត្រីឆ្តោ ត្រីឆ្លាំង ត្រីកេស ត្រីប៉ាវ៉ា ត្រីឆ្តោក ត្រីក្អែក ត្រីតានេល ត្រីក្រសក់ ត្រីគល់រាំង ត្រីខ្យា ត្រីខ្លា ត្រីកញ្ចុះ និងត្រីប្រមា។

២.ប្រភេទវារីសត្វ

អណ្តើក ពស់ ខ្យង ក្តាម អន្ទង់ ខ្ចៅ និងកង្កែប។

៣.ប្រភេទបក្សី

កុកស កុកក្រក មាន់ទឹក មាន់ ប្រវឹក ទាព្រៃ រនាលខ្យង ក្រសារ និងក្អែកទឹកក្អែកគោក។

៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ

រាំង ក្រស់ ត្នួរ ជ្រៃ សង្កែ ស្រឡៅ រៃ អណ្តែង ប្រធិញ ឬស្សី និងចង្កេង។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៨៧គ្រួសារ
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍ រស់នៅក្នុងសហគមន៍មានចំនួន១០៥គ្រួសារ
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៥០គ្រួសារ

ខ. ឧបករណ៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ ឧបករណ៍ នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | |
| សំណាញ់ ត្រីរៀល | វង់ | ១០១គ្រួសារ x២វង់ = ២០២វង់ | ១០៥គ្រួសារ x២វង់ = ២១០វង់ | ៥០គ្រួសារ x២វង់ = ១០០វង់ | ៧ម៉ែត្រ/ ១,៥ស.ម- ២,៥ស.ម | ៧ម៉ែត្រ/១,៥ ស.ម-២,៥ស .ម | ៧ម៉ែត្រ/ ១,៥ស .ម-២,៥ ស.ម | ពេញមួយឆ្នាំ |
| សំណាញ់ ត្រីធំ | វង់ | ១០១គ្រួសារ x២វង់ = ២០២វង់ | ១០៥គ្រួសារ x២វង់ = ២១០វង់ | ៥០គ្រួសារ x២វង់ = ១០០វង់ | ៧ម៉ែត្រ/ ៥ស.ម- ៧ស.ម | ៧ម៉ែត្រ/ ៥ស.ម- ៧ស.ម | ៧ម៉ែត្រ/ ៥ស.ម- ៧ស.ម | ពេញមួយឆ្នាំ |
| សន្ទូច បង្កៃ | ផ្លែ | ៨០គ្រួសារ x ៣០ផ្លែ = ៨០០០ផ្លែ | ៧០សារx៣០ ផ្លែ=៧០០០ ផ្លែ | ៥០គ្រួសារ x ៣០ផ្លែ = ៥០០០ផ្លែ | ផ្លែលេខ ១២-០៥ | ផ្លែលេខ១២- ០៥ | ផ្លែលេខ ១២-០៥ | ពេញមួយឆ្នាំ |
| លប | គ្រឿង | ៤០គ្រួសារ x៣ លប=១២០ | ៣០គ្រួសារx ៣លប=៩០ | | ១,៥ម៉ែត្រ- ២,៥ម៉ែត្រ | ១,៥ម៉ែត្រ- ២,៥ម៉ែត្រ | | ខែ៧-១០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | លប | លប | | | | | |
| ឈ្នាងត្រាំ | គ្រឿង | ៧០គ្រួសារ x ១០ឈ= ៧០០ឈ្នាង | ៥០គ្រួសារ x ១០ឈ= ៥០ឈ្នាង | | ០.៥ម៉ែត្រ-១ម៉ែត្រ | ០.៥ម៉ែត្រ-១ម៉ែត្រ | | ខែ៧-១០ |
| ចាន់ | គ្រឿង | ៧០គ្រួសារ x ១៥ចាន់= ១០៥០ឈ្នាង | ៥០គ្រួសារ x ១៥ចាន់= ៧៥០ | | | | | ខែ៧-១០ |
| សៃយ៉ឺន | គ្រឿង | ៧០គ្រួសារ x ២=១៤០ | ៥០គ្រួ x២ = ១០០ | | | | | ខែ៧-១០ |

ប្រភេទទូក កាណូត

| ប្រភេទទូកកាណូត | ចំនួន | | | ចំណុះ | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកចែវ | ៣៧ | ៣១ | ២០ | ១០០ | ១០០ | ១០០ | | | |
| ទូកអេវជាប់ម៉ាស៊ីន HONDA/HINOTA | ៥៥ | ៥១ | ៣០ | ២០០ ទៅ៣០០ | ២០០ ទៅ៣០០ | ២០០ ទៅ ៥០០ | ៥-១៣ | ៥-១៣ | ៥-១៨ |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១.១៤ | ៩១៩.៩១ | ១,៦៦១.០៥ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទភូមិអន្លង់ស្វាយមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោមៈ

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ ។

គ. គោលបំណងជាក់លាក់

- ការពារ និងដាំព្រៃលិចទឹកជាជម្រកត្រីនៅតាមអូរ
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ និង បណ្តុះផ្សិត និងរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយអាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ក្នុងទន្លេមេគង្គ | នេសាទពេញមួយឆ្នាំជាលក្ខណៈគ្រួសារ | សំណាញ់ | ២សម-៧សម | ៥វង់/គ្រួសារ | |
| | | ចាន់ | មុខកាត់ ០.៦ម៉ែត្រ | ១៥/គ្រួសារ | |
| | | លប | ១.៥សម-២.៥សម | ៣គ្រឿង/គ្រួសារ | |
| | | ឈ្នាងត្រាំ | មុខកាត់១ម កំពស់០.៥ម | ១០/គ្រួសារ | |
| | | សៃយឺន | មុខកាត់៨តឹក ប្រវែង១.៥ម | ២គ្រឿង/គ្រួសារ | |

ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែន នេសាទ | ទំហំ/ចំនួន | សកម្មភាព | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍អន្លង់ស្វាយ ១៥៨ ហិកតា | បង្គោលព្រំធ្វើពីស៊ីម៉ង់ ចំនួន៦ បង្គោល | -ផ្សព្វផ្សាយជាសាធារណៈ<br>-កំណត់ទីតាំងតាមនិយាមកា<br>-ទិញបង្គោលនិងយុទ្ធនាការចុះបោះបង្គោល | -គណៈកម្មការ<br>-សមាជិកស.ន<br>-មេភូមិ មេឃុំ | ៧/២០១៩ | ៦/២០២២ |
| | ផ្ទាំងប៉ាណូ ចំនួន ៣ផ្ទាំង | ផលិតនិងបោះផ្ទាំងប៉ាណូដែនទី/ការហាមឃាត់(ស្ត្រីនិងបុរសជាគណៈកម្មការសហគ មន៍នេសាទចូលរួមសម្រេចចិត្ត) | -គណៈកម្មការ<br>-សមាជិកស.ន<br>-មេភូមិ មេឃុំ | ៧/២០១៩ | ៦/២០២២ |

ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទ នៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់អភិរក្ស អូរឈើទាល | ០៧ | -ត្រីគ្រប់ប្រភេទ<br>-សត្វទឹកគ្រប់ប្រភេទ<br>-ព្រៃលិចទឹកគ្រប់ប្រភេទ | - កំណត់ព្រំប្រទល់កន្លែងអភិរក្ស<br>- ផលិត និងផ្សព្វផ្សាយផែនទីអន្លង់អភិរក្ស<br>- ផ្សព្វផ្សាយពីសារៈប្រយោជន៍កន្លែងអភិរក្ស (ស្ត្រីជាគណៈកម្មការសហគមន៍ នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>- បោះបង្គោលដាក់ស្លាកសញ្ញា<br>- សង់រោងយាម<br>- ចុះល្បាតជាប្រចាំ | ៧/២០១៩ | ៦/២០២២ | |

ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើ ដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ការថែរក្សាព្រៃលិចទឹកនៅសហគមន៍នេសាទភូមិអន្លង់ស្វាយ | ៤៣ ហិកតា | រាំងត្រស់ ពន្លា ឃ្លេរដែង និងប្រភេទ ព្រៃចំរុះ | - ប្រជុំផ្សព្វផ្សាយពី ផលប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកសញ្ញា ហាមកាប់ព្រៃលិចទឹក<br>- ចុះល្បាតជាប្រចាំ | ៧/២០១៩ | ៦/២០២២ | |

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|
| ដាំបន្លែ តាមបច្ចេកទេស លក្ខណៈគ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-វគ្គបណ្តុះបណ្តាល បច្ចេកទេសដាំបន្លែជាលក្ខណៈគ្រួសារ និងអនុវត្តផ្ទាល់<br>-ផ្តល់គ្រាប់ពូជបន្លែ និងទុន<br>- ត្រួតពិនិត្យនិងតាមដាន | គ្រាប់ពូជ បន្លែ ចម្រុះ(ស្ពៃ ត្រប់ ត្រកួន ត្រសក់ ប៉េងប៉ោះ...) | ២០ (១គ្រួសារ/ គ្រាប់ពូជ ៥ ប្រភេទ) | ៧/២០១៩ | ៦/២០២២ |
| បណ្តុះផ្សិតចំបើង/អំបោះ បច្ចេកទេសជាលក្ខណៈគ្រួសារ | - ជ្រើសរើសគ្រួសារកសិករ ស្ម័គ្រចិត្ត<br>- វគ្គបណ្តុះបណ្តាលបច្ចេក ទេសដាំផ្សិត អំបោះ និងផ្សិតចំបើងជាលក្ខណៈគ្រួសារ<br>- ត្រួតពិនិត្យ និងតាមដាន | មេផ្សិត ចំបើង និងផ្សិតអំបោះ | ១០ គ្រួសារ ផ្តល់ទុន/មេផ្សិត | ៧/២០១៩ | ៦/២០២២ |
| ចិញ្ចឹម មាន់/ទា តាម បច្ចេកទេសជាលក្ខណៈគ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹម មាន់/ទា តាមបច្ចេកទេស ជាលក្ខណៈគ្រួសារ<br>- អនុវត្តជាក់ស្តែងជាមួយ គ្រួសារកសិករ ធ្វើទ្រុង ផ្តល់ពូជចិញ្ចឹម/ទុន<br>- តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ៥០ គ្រួសារ (១០ក្បាល / ១គ្រួសារ) | ៧/២០១៩ | ៦/២០២២ |
| ចិញ្ចឹមជ្រូកតាម បច្ចេកទេសជាលក្ខណៈគ្រួសារ | - ជ្រើសរើសគ្រួសារកសិ ករស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹមជ្រូកតាម បច្ចេកទេស ជា លក្ខណៈគ្រួសារ និងអនុវត្តជាក់ស្តែង ជាមួយគ្រួសារកសិករ<br>- រៀបចំជ្រើសរើស ធ្វើទ្រុង និង ផ្តល់ពូជ/ទុន<br>- តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ១៥ គ្រួសារ (២ក្បាល/១ គ្រួសារ) | ៧/២០១៩ | ៦/២០២២ |
| ចិញ្ចឹមគោ តាម បច្ចេកទេសជាលក្ខណៈគ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍ | ពូជក្នុងស្រុក | ១០ គ្រួសារ (១ក្បាល/១ គ្រួសារ) | ៧/២០១៩ | ៦/២០២២ |

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|
| | - ផ្តល់ពូជ/ទុន<br>- ត្រួតពិនិត្យតាមដាន | | | | |

ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ៣០គ្រួសារចិញ្ចឹមត្រីចម្រុះ តាមបច្ចេកទេសជាលក្ខណៈគ្រួសារ (១០គ្រួសារ/១ឆ្នាំ) | -ជ្រើសរើសគ្រួសារ កសិករស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ<br>-ធ្វើអាង/បែរ/ស្រះ និងដាក់កូនត្រីចិញ្ចឹម<br>-ត្រួតពិនិត្យតាម ដាន | ៣០ស្រះ/អាង/បែរ<br>ទំហំ ៧ម x ៦ម | ត្រីចម្រុះ | ១០០០០ក្បាល | ៧/២០១៩ | ៦/២០២២ |

ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ ១ក្រុម (១ក្រុមមានសមាជិក ១៥-២០នាក់ ) | -ផ្សព្វផ្សាយទស្សនៈក្រុមសន្សំ ដល់សហគមន៍<br>-ជ្រើសរើសអ្នកទទួលផល<br>-បោះឆ្នោតជ្រើសរើសមេដឹកនាំ<br>-បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>-ផ្តល់ទុនដល់ក្រុម<br>-ត្រួតពិនិត្យតាមដាន | ៧/២០១៩ | ៦/២០២២ | |
| ពង្រឹងក្រុមសន្សំដែលមានស្រាប់មាន៥ក្រុម | -ផ្សព្វផ្សាយទស្សនៈក្រុមសន្សំ ដល់សហគមន៍<br>-ជ្រើសរើសអ្នកទទួលផល<br>-បោះឆ្នោតជ្រើសរើសមេដឹកនាំ<br>-បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>-ផ្តល់ទុនដល់ក្រុម<br>-ត្រួតពិនិត្យតាមដាន | ៧/២០១៩ | ៦/២០២២ | |

ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|
| បង្កើតកន្លែងលក់ដូរក្នុងទីតាំងកន្លែងទេសចរណ៍ក្នុងភូមិ | ០១ កន្លែង | ៧/២០១៩ | ៦/២០២២ |
| អណ្តូងស្នប់ | ០៧ កន្លែង | ៧/២០១៩ | ៦/២០២២ |
| អណ្តូងលូ | ០៧ កន្លែង | ៧/២០១៩ | ៦/២០២២ |
| ជួសជុលផ្លូវលំគ្រួសក្រហម ១ខ្សែ | ៦០០ម | ៧/២០១៩ | ៦/២០២២ |
| តប្រព័ន្ធទឹកពីលើភ្នំមកប្រើតាមផ្ទះ | ១០០គ្រួសារ | ៧/២០១៩ | ៦/២០២២ |

ឃ.៣. ការគ្រប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើសនេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៣ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | ២ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ផ្តល់សម្ភារល្បាត (១ឈុត) | អាវពោង | ៧ អាវ | ២០១៩ | ២០១៩ |
| | អាវភ្លៀង | ៧ អាវ | | |
| | គោមបំភ្លឺពាក់ក្បាល | ៧ គោម | | |
| | វិទ្យុទាក់ទង | ៧ គ្រឿង | | |
| | កែវយឺត | ២ គ្រឿង | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | |
| | អង្រឹង | ៧ អង្រឹង | | |
| | តង់គ្របទូក ៤មគុណ៦ម | ១ តង់ | | |
| | សម្ភារត្រួតពិនិត្យទឹក | ១ កំប្លេ | | |
| | ស្លាបចក្រ | ៦ គ្រឿង | | |
| | សោរសម្រាប់ជួសជុលទូក | ១ សម្រាប់ | | |
| | សោរច្រវាក់ចាក់ទូក | ២ សោរ | | |
| ទិញទូកស្ទាច់ម៉ាស៊ីន (១៣-១៨ សេះ) | | ២ គ្រឿង | ២០១៩ | ២០១៩ |
| ប្រេងសម្រាប់ល្បាត | | ៥០ លីត្រ/ខែ | ៧/២០១៩ | ៦/២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ | | ១ កន្លែង | ៧/២០១៩ | ៦/២០២២ |

ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ៧/២០១៩ | ៦/២០២២ |
| ចូលរួមប្រជុំបណ្តាញសហគមន៍នេសាទ | តាមការអញ្ជើញ | ៧/២០១៩ | ៦/២០២២ |
| យុទ្ធនាការហែរក្បួនបំផុសការយល់ដឹងអំពី ច្បាប់ជលផល និង សារៈប្រយោជន៍នៃធនធានជលផល | ១ដង/១ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលគណៈកម្មការសហគមន៍នេសាទស្តីពីច្បាប់ជលផល | ១លើក | ២០១៩ | ២០១៩ |
| បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ និងរបាយការណ៍ | ១លើក | ២០១៩ | ២០១៩ |
| បណ្តុះបណ្តាលជំនាញរៀបចំផែនការគ្រប់គ្រង | ១លើក | ២០២០ | ២០២០ |
| បណ្តុះបណ្តាលជំនាញសម្របសម្រួល | ១លើក | ២០២០ | ៦/២០២២ |
| បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០២០ | ៦/២០២២ |
| បណ្តុះបណ្តាលរបៀបគ្រប់គ្រងបញ្ជីចំណូល និងចំណាយ | ១លើក | ២០២០ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក | ២០២០ | ៦/២០២២ |
| ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក | ២០២០ | ៦/២០២២ |

ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | ២ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយដែននេសាទសហគមន៍ | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៧/២០១៩ | ៦/២០២២ |

ឃ.៣.៤ ផែនការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាម | ៧/២០១៩ | ៦/២០២២ | គណៈកម្មការសហគមន៍នេសាទ | |

| | | | | |
|---|---|---|---|---|
| រយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៧/២០១៩ | ៦/២០២២ | គណៈកម្មការសហគមន៍នេសាទ | |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកថ្មី | ចុះប្រមូលប្រាក់សមាជិកភាព | ៧/២០១៩ | ៦/២០២២ | | |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលភាគទានប្រចាំឆ្នាំ | ៧/២០១៩ | ៦/២០២២ | ១៣០,៥០ | |
| ភាគទានពីអ្នកនេសាទខាងក្រៅ ឬអ្នក មិនមែនជាសមាជិកសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅ | ៧/២០១៩ | ៦/២០២២ | ៥.៦៧០,០០ | |
| | ប្រមូលប្រាក់ភាគទានពីអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | ១៣.៥០០,០០ | |
| • ភាគលាភពីក្រុមចិញ្ចឹមជីវិតរបស់ស.ន<br>• បដិភាគពីរាជរដ្ឋាភិបាល<br>• អំណោយពីសប្បុរសជន<br>• ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល | -បញ្ចូលផែនការអភិវឌ្ឍសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់<br>-ទំនាក់ទំនងជាមួយស្ថាប័នដលផល<br>-សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ៧/២០១៩ | ៦/២០២២ | ៦៤.២១៩,៥០ | |

### ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | គណៈកម្មការ សហគមន៍នេសាទ | |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច | ៧/២០១៩ | ៦/២០២២ | គណៈកម្មការ សហគមន៍នេសាទ | |

### ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមាន សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទ ចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រី និងជនជាតិភាគតិច ជាសមាជិកសហគមន៍ចូលរួមកិច្ចប្រជុំ និងចូលរួមសកម្មភាពនានារបស់សហគមន៍នេសាទ។
- ជ្រើសរើសស្ត្រី៥០% ជាសមាជិកសហគមន៍ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព ក្នុងនោះស្ត្រីមេគ្រួសារ ៧%
- ផ្តល់ឱកាសដល់ស្ត្រីជាសមាជិកសហគមន៍ នៃអ្នកទទួលផលសរុបទទួលបានផលប្រយោជន៍ពីគម្រោង
- លើកទឹកចិត្តស្ត្រីជាគណៈកម្មការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រី ជាគណៈកម្មការមិនបោះបង់ការងារ
- រៀបចំការប្រជុំឱ្យស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណៈកម្មការសហគមន៍នេសាទ។

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៦០x២=១២០ | អង្គការដៃគូ រដ្ឋបាលជលផល ថវិកាសហគមន៍ | ៧/២០១៩ | ៦/២០២២ | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | បោះបង្គោលព្រំធ្វើពីស៊ីម៉ង់ចំនួន ០៦ បង្គោល | ០៦ បង្គោល | ៧០០x៦=៤.២០០ | អង្គការដៃគូ រដ្ឋបាលជលផល | ២០១៩ | ២០១៩ | |
| | តម្លើងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទចំនួន ០៣ផ្ទាំង | ០៣ផ្ទាំង | ៣០០x៣= ៩០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | ផលិត និងផ្សព្វផ្សាយផែនទីអន្លង់អភិរក្ស | ផែនទីអន្លង់អភិរក្សចំនួន ១ផ្ទាំង | ៨.០០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | បោះបង្គោលដាក់ស្លាកសញ្ញា | ស្លាកសញ្ញាចំនួន ២ស្លាក | | | ៧/២០១៩ | ៦/២០២២ | |
| | សង់រោងយាម | រោងយាមចំនួន ១ | | | ៧/២០១៩ | ៦/២០២២ | |
| ឃ.១.៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក | ១០ ផ្ទាំង | ៣០x១០=៣០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| ឃ.២. ការរួចជីវភាពប្រជាពលរដ្ឋ | | | | | | | |



te

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | រៀបចំសូនបន្លែតាមលក្ខណៈគ្រួសារ | ២០ គ្រួសារ | ៣០០x២០= ៦.០០០ | អង្គការដៃគូ រដ្ឋបាល ជលផល | ៧/២០១៩ | ៦/២០២២ | |
| | បណ្ដុះផ្សិតចំបើង/អំបោះ បច្ចេកទេសជាលក្ខណៈគ្រួសារ | ១០ គ្រួសារ | ៣០០x១០= ៣.០០០ | | ៧/២០១៩ | ៦/២០២២ | |
| | ចិញ្ចឹមមាន់ទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៥០ គ្រួសារ | ៣០០x៥០= ១៥.០០០ | | ៧/២០១៩ | ៦/២០២២ | |
| | ចិញ្ចឹមជ្រូកតាម បច្ចេកទេសជាលក្ខណៈគ្រួសារ | ១៥ គ្រួសារ | ៣០០x១៥=៤.៥០០ | | ៧/២០១៩ | ៦/២០២២ | |
| | ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ១០ គ្រួសារ | ៣០០x១០= ៣.០០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីចម្រុះ តាមបច្ចេកទេសជាលក្ខណៈគ្រួសារ(១០គ្រួសារ/១ឆ្នាំ) | ៣០ គ្រួសារ | ៣០០x៣០= ៩.០០០ | អង្គការដៃគូ រដ្ឋបាល ជលផល | ៧/២០១៩ | ៦/២០២២ | |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | បង្កើតក្រុមសន្សំប្រាក់ ១ក្រុម (១ក្រុមមាន១៥-២០នាក់ | ១ក្រុម (១ក្រុមមាន១៥-២០នាក់ | ១.០០០ | អង្គការដៃគូ រដ្ឋបាល ជលផល | ៧/២០១៩ | ៦/២០២២ | |
| | ពង្រឹងក្រុមសន្សំដែលមានស្រាប់ | ៥ក្រុម | ៥០០x៥= ២.៥០០ | | | | |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | បង្កើតកន្លែងលក់ដូរក្នុងទីតាំងកន្លែង ទេសចរណ៍ក្នុងភូមិ | ០១ កន្លែង | ១០.០០០ | អង្គការដៃគូ រ.ជលផល រដ្ឋាភិបាល | ៧/២០១៩ | ៦/២០២២ | |
| | សាងសង់អណ្ដូងស្អប់ | ០៧ កន្លែង | ២០០០*៧= ១៤០០០ | | ៧/២០១៩ | ៦/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សាងសង់អណ្តូងលូ | ០៧ កន្លែង | ១០០០*៧=៧០០០ | | ៧/២០១៩ | ៦/២០២២ | |
| | ជួសជុលផ្លូវលំគ្រួសក្រហម-ដាក់លូ | ១ខ្សែ (៦០០ម) | ១០០០០*១= ១០០០០ | | ៧/២០១៩ | ៦/២០២២ | |
| | តប្រព័ន្ធទឹកពីលើភ្នំមកប្រើតាមផ្ទះ | ១០០ គ្រួសារ | ៥០០០*១០០= ៥០០០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | សហគមន៍ចុះល្បាតដោយខ្លួនឯង | ២ដង/ខែ | ៤.៥០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | ៣ដង/១ខែ | | | | | |
| | ប្រេងសម្រាប់ល្បាត | ៥០លីត្រ/១ខែ | | | | | |
| | សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | ២ដង/ឆ្នាំ | | | | | |
| | បំពាក់សម្ភារល្បាត | ១ឈុត | ១.០០០ | | ២០១៩ | ២០១៩ | |
| | ទិញទូកស្ទាច់ម៉ាស៊ីន | ២គ្រឿង (១តូច ១ធំ) | ៣.០០០ | | ២០១៩ | ២០១៩ | |
| | សាងសង់ទីស្នាក់ការសហគមន៍ | ស្នាក់ការចំនួន១ បានសាងសង់ | ៣.០០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ១៥០ | អង្គការដៃគូ រដ្ឋបាលជលផល សហគមន៍ | ៧/២០១៩ | ៦/២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |



tl

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ចូលរួមប្រជុំបណ្ដាញសហគមន៍នេសាទ | តាមការអញ្ជើញ | ៣០០ | | ៧/២០១៩ | ៦/២០២២ | |
| | យុទ្ធនាការហែរក្បួនបំផុសការយល់ដឹងអំពី ច្បាប់ជលផល និងសារៈប្រយោជន៍នៃធនធានជលផល (សមាជិកទាំងអស់) | ១ដង/១ឆ្នាំ | ៥០០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្ដុះបណ្ដាលគណកម្មការសហគមន៍នេសាទពីច្បាប់ជលផល | ១ ដង | ១០០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្ដុះបណ្ដាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ១០០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្ដុះបណ្ដាលជំនាញរៀបចំផែនការគ្រប់គ្រង | ១លើក | ១០០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្ដុះបណ្ដាលអំពីជំនាញសម្របសម្រួល | ១លើក | ១០០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្ដុះបណ្ដាលការដោះស្រាយទំនាស់ | ១លើក | ១០០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្ដុះបណ្ដាលរបៀបគ្រប់គ្រងបញ្ជីចំណូលចំណាយ | ១លើក | ១០០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្ដុះបណ្ដាលអំពីភាពជាអ្នកដឹកនាំ | ១លើក | ១០០ | | ៧/២០១៩ | ៦/២០២២ | |
| | ទស្សនកិច្ចសិក្សាផ្លាស់ប្ដូរបទពិសោធន៍ | ១លើក/១ឆ្នាំ | ១.០០០ | | ៧/២០១៩ | ៦/២០២២ | |



ស

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ១ដង/ឆ្នាំ | ៩០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយផែនទីនេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | ១ដង/ឆ្នាំ | | | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | | | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ១ដង/ឆ្នាំ | | | ៧/២០១៩ | ៦/២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | | | ៧/២០១៩ | ៦/២០២២ | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទ សមភាព និងសមធម៌ យេនឌ័រ | ១ដង/ឆ្នាំ | ២០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទានមហាសន្និបាតប្រចាំឆ្នាំ | ២ដង/ឆ្នាំ | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ | ១ដង/ឆ្នាំ | | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់ | ភាគទានពីសមាជិកសហគមន៍ | សមាជិកសហគមន៍ បានបង់ភាគទានសមាជិកភាព | | ថវិកាសហគមន៍ | ៧/២០១៩ | ៦/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| អភិវឌ្ឍន៍សហគមន៍ | ភាគទានសមាជិកប្រចាំឆ្នាំ | ១ ឆ្នាំម្តង | ១៣០,៥ | | ៧/២០១៩ | ៦/២០២២ | |
| | ភាគទានពីអ្នកនេសាទខាងក្រៅ ឬអ្នក មិនមែនជាសមាជិកសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅ | ៥.៦៧០ | ភាគទានពីអ្នកនេសាទខាងក្រៅ | ៧/២០១៩ | ៦/២០២២ | |
| | | ប្រមូលប្រាក់ភាគទានពីអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ១៣.៥០០ | ប្រាក់ភាគទានពីអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពផ្សេងៗ | ១៤៥២១៩,៥០ | អង្គការដៃគូ រដ្ឋបាល ជលផល | ៧/២០១៩ | ៦/២០២២ | |
| ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៤ត្រីមាស/ឆ្នាំ | | អង្គការដៃគូ រដ្ឋបាល ជលផល | ៧/២០១៩ | ៦/២០២២ | |
| | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី និងជនជាតិភាគតិច | ១ដង/ឆ្នាំ | ៦០០ | | | | |

## តារាងកម្មវិធីការងារប្រចាំឆ្នាំ កក្កដា ២០១៩ - មិថុនា ២០២២

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | | | | | X | | | | | X | | | | | | | X | | | | | X | | | | | | | X | | | | | X | | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បោះបង្គោលព្រំធ្វើពីស៊ីម៉ង់ ចំនួន០៦ បង្គោល | | | | | | | | | X | X | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ០៣ផ្ទាំង | | | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផលិត និងផ្សព្វផ្សាយផែនទីអន្លង់អភិរក្ស | | | | | | | | | | X | X | X | | | | | | | | | | X | X | X | | | | | | | | | | X | X | X |
| បោះបង្គោលដាក់ស្លាកសញ្ញា | | | | | | | | | | | | | X | X | X | | | | | | | | | | | | | | | | | | | | | |
| សាងសង់រោងយាម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ស្លាកសញ្ញាហាមកាប់ព្រៃ | | | | | | | | | | | | | X | X | X | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| លិចទឹក ចំនួន ២០ផ្ទាំង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បណ្តុះផ្សិតចំបើង/អំបោះ បច្ចេកទេសលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមមាន់ទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីចម្រុះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បង្កើតក្រុមសន្សំប្រាក់ ១ក្រុម (១ក្រុមមាន១៥-២០នាក់) | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ពង្រឹងក្រុមសន្សំដែលមានស្រាប់ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| បង្កើតកន្លែងលក់ដូរក្នុង ទីតាំងកន្លែង ទេសចរណ៍ក្នុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **ឃ.៣. ការងារគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតខ្លួនឯង | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បំពាក់សម្ភារល្បាត | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្ទាច់ម៉ាស៊ីន | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រេងសម្រាប់ល្បាត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សេវាជួសជុលនិងថែទាំទូកនិងម៉ាស៊ីន | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ទីស្នាក់ការសហគមន៍ | | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ / សង្កាត់ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំបណ្ដាញសហគមន៍នេសាទ | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ / សង្កាត់ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំបណ្តាញសហគមន៍នេសាទ | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| យុទ្ធនាការហែរក្បួនបំផុសការយល់ដឹងអំពី ច្បាប់ជលផល និងសារៈប្រយោជន៍នៃធនធានជលផល (សមាជិកទាំងអស់) | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | |
| បណ្តុះបណ្តាលគណកម្មការសហគមន៍នេសាទពីច្បាប់ជលផល | | | | | | | | | | | | X | | | | | | | | | | | | | | | | | | | | | | | | |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | X | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | | | | | | |
| បណ្តុះបណ្តាលជំនាញរៀបចំផែនការគ្រប់គ្រង | | X | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | | | | | |
| បណ្តុះបណ្តាលអំពីជំនាញសម្របសម្រួល | | | X | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | | | | |
| បណ្តុះបណ្តាលអំពីការដោះស្រាយជម្លោះ | | | | X | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| បណ្តុះបណ្តាលរបៀបគ្រប់គ្រងបញ្ជីចំណូលចំណាយ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| យ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | | X | | | | | | | | X | | | | X | | | | | | | | X | | | | X | | | | | | | | X | | |
| ផ្សព្វផ្សាយផែននេសាទ និងកន្លែងអភិរក្សរបស់សហគមន៍ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | |
| ប្រព័ន្ធផ្សព្វផ្សាយអំពីតួនាទីរបស់ស្ត្រីក្នុងសហគមន៍នេសាទ | | | | X | | | | | | | | | | | X | | | | | | | | | | | | | X | | | | | | | | |
| យ.៣.៤ ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

លេខ ០០៤....៥៨៥

បានឃើញ និងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

" ដើម្បីពិនិត្យ និងសម្រួល"

ថ្ងៃ.......ខែ.......ឆ្នាំ.......ព.ស ២៥៦៣

ថាឡាបរិវ៉ាត់ ថ្ងៃទី ២៩ ខែ ១សភា ឆ្នាំ២០១៩

ហ. នាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់

លេខ ១០...........៣៩

បានឃើញ និងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់

" ដើម្បីពិនិត្យ និងសម្រួល"

ថ្ងៃ.......ខែ.......ឆ្នាំ.......ព.ស ២៥៦៣ ឃុំព្រះរំកិល ថ្ងៃទី ២៧ ខែ ១សភា ឆ្នាំ២០១៩

មេឃុំព្រះរំកិល

សូមគោរពជូន

លោកមេឃុំព្រះរំកិល

" ដើម្បីពិនិត្យ និងសម្រួល"

ថ្ងៃ.......ខែ.......ឆ្នាំ.......ព.ស ២៥៦៣

ភូមិអន្លង់ស្វាយ ថ្ងៃទី ១៧ ខែ ១សភា ឆ្នាំ២០១៩

ប្រធានគណៈកម្មការសហគមន៍នេសាទភូមិអន្លង់ស្វាយ

ភិន - ឃុំ ...

តឹប ម៉ឿងឃុន

លេខ ១៦៧៣

បានឃើញ និងឯកភាព

ថ្ងៃ.......ខែ.......ឆ្នាំ.......ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៩

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

អេង ជាសាន

លេខ :.............

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ.......ខែ.......ឆ្នាំ.......ព.ស ២៥៦៣

ស្ទឹងត្រែង ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៩

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

លៀង_សេង

លេខ ០១៣៧/១៩......

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

" ដើម្បីពិនិត្យ និងសម្រួល"

ថ្ងៃ.......ខែ.......ឆ្នាំ.......ព.ស ២៥៦៣

ស្ទឹងត្រែង ថ្ងៃទី ៣០ ខែ ១សភា ឆ្នាំ២០១៩

នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

ទុំ នារី